# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ អនក្រ

## សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការជំនាញសម្រាប់បារាយណ៍ទឹកថ្លា ខេត្តសៀមរាប

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្ដីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរអប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្ដីពី ការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរអប្សរា ឱ្យស្របជាមួយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យ លេខ នស/ រកត /១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលក្ខន្តិកៈ-តតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្ដីពី ការកែសម្រួលមាត្រា៤ និង មាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្ដីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរអប្សរា ឱ្យស្របជាមួយបទប្បញ្ញត្តិ នៃព្រះរាជក្រឹត្យ លេខ នស/ រកត /១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលក្ខន្តិកៈ-តតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលមាត្រា៦ និងមាត្រា១៤ នៃអនុក្រឹត្យលេខ ១៥.អនក្រ .បក. ចុះ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរអប្សរា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត គណៈកម្មការជំនាញសម្រាប់បារាយណ៍ទឹកថ្លា ខេត្តសៀមរាប ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ជុំច គឿន | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២-ឯកឧត្តម ខេង សាខុន | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣-ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤-ឯកឧត្តម ប៊ុន ណារិទ្ធ | អគ្គនាយក អាជ្ញាធរអប្សរា | អនុប្រធានអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តម ស៊ូ ភិរិន្ទ | អភិបាល ខេត្តសៀមរាប | សមាជិក |
| ៦-ឯកឧត្តម ញាណ ឡេង | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោកជំទាវ គាន់ ធានី | អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិយូណេស្កូកម្ពុជា | សមាជិក |
| ៨-លោក ចុង សុខគ្គី | អគ្គនាយករង បច្ចេកទេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៩-លោក ហង់ ពៅ | ប្រធាន នាយកដ្ឋានទឹក និងព្រៃឈើ របស់អាជ្ញាធរអប្សរា | សមាជិក |
| ១០-លោក សម នៅ | អនុប្រធាន នាយកដ្ឋានរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១-លោក Michel Verrot | ស្ថាបត្យករ ទីប្រឹក្សាផ្នែកប្រាសាទបុរាណ | ទីប្រឹក្សា |
| ១២-លោក Azedine BESCHAOUCH | ទីប្រឹក្សាផ្នែកបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូ | ទីប្រឹក្សា |

**ប្រការ ២.-**

គណៈកម្មការជំនាញសម្រាប់បារាយណ៍ទឹកថ្លា ខេត្តសៀមរាប មានភារកិច្ចដូចតទៅ

-ចុះពិនិត្យ និងវាយតម្លៃលើការខូចខាតខ្លងទំនប់បារាយណ៍ទឹកថ្លាក្នុងពេលកន្លងមក

-លើកវិធានការ និងកម្មវិធីការងារថ្មី ដើម្បីជួសជុលខ្លួនទំនប់បារាយណ៍ដែលរងការខូចខាតកន្លងទៅ និងបង្កើនបរិមាណទឹកក្នុងបារាយណ៍ទឹកថ្លា

-ពិគ្រោះយោបល់ជាមួយវិស្វករផ្នែកតាមការចាំបាច់ ដើម្បីឱ្យការងារនេះមានភាពរលូន

-បង្កើតប្រព័ន្ធត្រួតពិនិត្យ តាមដានការងារជួសជុលបារាយណ៍ទឹកថ្លាជាប្រចាំ

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារដែលសម្រេចបាន ជូនប្រធានអាជ្ញាធរអប្សរា។

**ប្រការ ៣.-**

សមាជិកគណៈកម្មការជំនាញសម្រាប់បារាយណ៍ទឹកថ្លា ខេត្តសៀមរាប ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ ប្រធាន។

**ប្រការ ៤.-**

គណៈកម្មការជំនាញសម្រាប់បារាយណ៍ទឹកថ្លា ខេត្តសៀមរាបមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់អាជ្ញាធរអប្សរា។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រធានអាជ្ញាធរអប្សរា, រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, រដ្ឋមន្ត្រីក្រសួងទេសចរណ៍, រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ប្រធានគណៈកម្មាធិការជាតិយូណេស្កូកម្ពុជា អភិបាលខេត្តសៀមរាប, រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ០៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com